ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
លេខ ....ក.ប/ប្រ.ក

ប្រកាស
ស្តីពី
បែបបទ និងនីតិវិធីក្នុងការពិន័យអន្តរការណ៍ចំពោះ
បុគ្គលប្រព្រឹត្តអំពើល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់ស្តីពីរបបសន្តិសុខសង្គម

រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពី ការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពី ការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពី ការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៥០/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៨ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបសន្តិសុខសង្គម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥២០/៥៨២ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២០ ស្តីពី ការបង្កើតបេឡាជាតិសន្តិសុខសង្គម ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ២៣៦ អនក្រ.បក ចុះថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០២៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ១៩៦ អនក្រ.បក ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់បេឡាជាតិសន្តិសុខសង្គម (ប.ស.ស.)

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទៈ(០២៣)៨៨ ៤៣ ៧៥ និងទូរសារៈ(០២៣)៨៨ ២៧ ៦៩

- បានឃើញអនុក្រឹត្យ១៤៤ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ ២០២១ ស្តីពីការកំណត់ប្រាក់ឈ្នួល ឬប្រាក់បៀវត្សជាប់ភាគទាន
- បានឃើញអនុក្រឹត្យលេខ១១៩ អនក្រ.បក ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០២៣ ស្តីពីការតែងតាំងនិងតួនាទីភារកិច្ចរបស់អធិការសន្តិសុខសង្គម
- បានឃើញប្រកាសអន្តរក្រសួងលេខ៣២៦/២២ កប/ប្រ.ក.ខ.ល ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២២ ស្តីពីប្រាក់ឈ្នួលយោងប្រចាំថ្ងៃ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ

សម្រេច

ប្រការ១ .-

ប្រកាសនេះ កំណត់អំពីបែបបទ និងនីតិវិធីក្នុងការពិន័យអន្តរការណ៍ចំពោះសហគ្រាស ក្រុមហ៊ុន រោងចក្រ ដែលប្រព្រឹត្តអំពើល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់ស្តីពីរបបសន្តិសុខសង្គម ដើម្បីធានាដល់ការអនុវត្តច្បាប់ស្តីពីរបបសន្តិសុខសង្គម ប្រកបដោយប្រសិទ្ធភាព និងតម្លាភាព។

ប្រការ២ .-

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះនិយោជក និងបុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដោយរួមបញ្ចូលទាំងបុគ្គលិកធ្វើការតាមផ្លូវអាកាស និងនាវាសមុទ្រ ព្រមទាំងអ្នកបម្រើក្នុងផ្ទះ។

ប្រការ៣ .-

និយោជកដែលបានប្រព្រឹត្តអំពើល្មើសដូចមានចែងក្នុងមាត្រា៩៨ នៃច្បាប់ស្តីពីរបបសន្តិសុខសង្គម ត្រូវទទួលរងការពិន័យអន្តរការណ៍ ដូចមានកំណត់ក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ។

ប្រាក់ឈ្នួលយោងប្រចាំថ្ងៃសម្រាប់ការគណនាប្រាក់ពិន័យអន្តរការណ៍ ត្រូវអនុវត្តតាមប្រកាសអន្តរក្រសួងរវាងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងយុត្តិធម៌ស្តីពីប្រាក់ឈ្នួលយោងប្រចាំថ្ងៃជាធរមាន។

ករណីដែលនិយោជកបានប្រព្រឹត្តអំពើល្មើសច្រើនក្នុងពេលតែមួយ ត្រូវរងពិន័យអន្តរការណ៍ទៅតាមអំពើល្មើសនីមួយៗ។

ការពិន័យអន្តរការណ៍នេះមិនទាន់រាប់បញ្ចូលនូវវិធានការផ្សេងៗ ជាអាទិ៍ ការបង់រំលឹកភាគទានដែលបានបង់មិនត្រឹមត្រូវ និងការទូទាត់សំណងតាវកាលិកផ្សេងៗជូនកម្មករនិយោជិតស្របតាមបទប្បញ្ញត្តិជាធរមាន។

ប្រការ៤ .-

អធិការសន្តិសុខសង្គមត្រូវរៀបចំសំណុំឯកសារពាក់ព័ន្ធសហគ្រាស ក្រុមហ៊ុន រោងចក្រ និងស្នើសុំគោលការណ៍ទៅអគ្គនាយក **ប.ស.ស**. ដើម្បីធ្វើការពិន័យអន្តរការណ៍ចំពោះបុគ្គលដែលប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់ស្តីពីរបបសន្តិសុខសង្គម។

បុគ្គលដែលប្រព្រឹត្តល្មើសត្រូវបង់ប្រាក់ពិន័យអន្តរការណ៍ក្នុងរយៈពេល ១៥(ដប់ប្រាំ)ថ្ងៃ បន្ទាប់ពីទទួលបានលិខិតពិន័យអន្តរការណ៍។ ក្នុងករណីមិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍ អគ្គនាយក **ប.ស.ស**. ត្រូវរៀបចំសំណុំរឿងបញ្ជូនទៅតុលាការមានសមត្ថកិច្ចដើម្បីចាត់ការតាមនីតិវិធី។

ប្រការ៥ .-

អគ្គលេខាធិការ អគ្គនាយកបេឡាជាតិសន្តិសុខសង្គម អគ្គនាយកនៃអគ្គនាយកដ្ឋានអធិការកិច្ចការងារ អគ្គនាយកនៃអគ្គនាយកដ្ឋានទំនាក់ទំនងវិជ្ជាជីវៈនិងដោះស្រាយវិវាទការងារក្រៅប្រព័ន្ធតុលាការ ប្រធានគ្រប់អង្គភាពពាក់ព័ន្ធ និងប្រធានមន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមការកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ក្រហោ ខែ មេសា ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២៦

រដ្ឋមន្ត្រី

ហេង សួរ

កន្លែងទទួលៈ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ឧទ្ធកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ឧទ្ធកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៥
- រដ្ឋបាលរាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃប្រកាសលេខ: ២៧៥/ប្រក.ល/ប្រ.ភ ចុះថ្ងៃទី ៦ ខែ វិច្ឆិកា ឆ្នាំ២០២៦

ស្តីពីបែបបទ និងនីតិវិធីក្នុងការពិន័យអន្តរការណ៍ចំពោះបុគ្គលប្រព្រឹត្តអំពើល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់ស្តីពីរបបសន្តិសុខសង្គម

ល.រ.	អំពើល្មើស	ចំណុចល្មើស	ល្មើសនឹងមាត្រា	ពិន័យយោងតាមមាត្រា	កម្រិតនៃការពិន័យគិតជាដង	ប្រាក់ឈ្នួលយោងប្រចាំថ្ងៃ(រៀល)	ចំនួនកម្មកររនិយោជិតល្មើសជាក់ស្តែង	ប្រាក់ពិន័យ (រៀល)
១	២	៣	៤	៥	៦	៧	៨	៩
ក	ការមិនអនុវត្តកាតព្វកិច្ចបង់ភាគទានតាមកាលកំណត់	- មិនចុះបញ្ជីសហគ្រាស ក្រុមហ៊ុន រោងចក្រ ឬកម្មកររនិយោជិត - មិនបានបង់ភាគទាន ក្រោយដំណាច់ខែនីមួយៗ - បង់ភាគទានយឺត ក្រោយថ្ងៃទី២០ នៃខែនីមួយៗ	មាត្រា៨២	មាត្រា៩៨	- កំហុសលើកទី១ គុណនឹង ១០ដង - កំហុសលើកទី២ គុណនឹង ២០ដង - កំហុសចាប់ពី ៣លើកឡើង គុណនឹង ៣០ដង	៨០ ០០០	ចំនួនកម្មកររនិយោជិតល្មើសជាក់ស្តែង	៩ = ៦×៧×៨
ខ	ការមិនអនុវត្តកាតព្វកិច្ចរាយការណ៍ពីកម្មកររនិយោជិតឱ្យបានត្រឹមត្រូវ	- មិនផ្តល់របាយការណ៍កម្មកររនិយោជិតក្រោយដំណាច់ខែនីមួយៗ - ផ្តល់របាយការណ៍ចំនួនកម្មកររនិយោជិតយឺត ក្រោយថ្ងៃទី២០ នៃខែនីមួយៗ - រាយការណ៍ចំនួនកម្មកររនិយោជិតមិនត្រឹមត្រូវ - ចុះបញ្ជីបុគ្គលដែលមិនមែនជាកម្មកររនិយោជិតបម្រើការងារក្នុងសហគ្រាស ក្រុមហ៊ុន រោងចក្រ របស់ខ្លួន - ប្រកាសប្រាក់ឈ្នួលជាប់ភាគទានមិនត្រឹមត្រូវ	មាត្រា៨២	មាត្រា៩៨	- កំហុសលើកទី១ គុណនឹង ១០ដង - កំហុសលើកទី២ គុណនឹង ២០ដង - កំហុសចាប់ពី ៣លើកឡើង គុណនឹង ៣០ដង	៨០ ០០០	ចំនួនកម្មកររនិយោជិតល្មើសជាក់ស្តែង	៩ = ៦×៧×៨